ខ្ញុំមានតំលៃ
I am Precious
Garment Workers Value Campaign and Competition

# ជីវិតពិតរបស់អ្នកឈ្នះ នៅក្នុងការប្រកួតដែលមានឈ្មោះថា " ខ្ញុំមានតំលៃ "

" ខ្ញុំមានតំលៃ " គឺជាការប្រកួតរចនាម៉ូតសំលៀកបំពាក់ និង តែងបទចំរៀងជាលើកដំបូងបង្អស់ដែលបង្ហាញពីទេពកោសល្យនៅពីក្រោយរបស់កម្មករ_កម្មការនី រោងចក្រកាត់ដេរនៅកម្ពុជា ។ ការប្រកួតនេះបានទាក់ទាញអោយមានការដាក់ពាក្យចូលរួមប្រកួតបញ្ចេញស្នាដៃ ពីសំណាក់បេក្ខជនគូរម៉ូតសំលៀកបំពាក់ និង តែងបទចំរៀងជាងបួនរយពាក្យ ។ គោលបំណងក្នុងការបង្កើតជាការប្រកួតនេះឡើង គឺដើម្បីបង្ហាញនៅការទទួលស្គាល់ពីសមត្ថភាព និង ជំនាញដ៏ប៉ិនប្រសព្វរបស់កម្មករ_កម្មការនីកាត់ដេរ ហើយជាពិសេសជាងនេះទៅទៀតគឺចង់បង្ហាញពីតំលៃ និង សមត្ថភាពផ្សេងៗទៀតដែលពួកគាត់អាចធ្វើបានក្រៅពីការងាររោងចក្រ ។ ខាងក្រោមនេះ គឺជាអ្នកជាប់ជ័យលាភីទាំង៦រូប ដែលបានចូលរួមចែករំលែកនូវបទពិសោធន៍ ក៏ដូចជាបង្ហាញពីអារម្មណ៏ផ្ទាល់របស់ពួកគាត់ បន្ទាប់ពីបានទទួលតំណែងជ័យលាភីខាងផ្នែករចនាម៉ូតសំលៀកបំពាក់ និងតែងបទចំរៀង ។ សំលៀកបំពាក់ដែលជាប់ជ័យលាភីមានបង្ហាញជូនខាងក្រោម ចំណែកបទចំរៀងដែលជាប់ជ័យលាភីក៏អាចដោនលតបានផងដែរ ។

## អ្នកជាប់ជ័យលាភីតែងបទចំរៀង

### ជ័យលាភីលេខ ១

### កញ្ញា តូច ស្រីនិត អាយុ ២៤ ឆ្នាំ ធ្វើការនូវរោងចក្រ ហុងវ៉ា សាខាទី១



នៅថ្ងៃប្រកួតបានមកដល់ខ្ញុំបានអង្គុយនៅពីមុខវេទិកាជាមួយនឹងអ្នកនិពន្ធផ្សេងទៀតក្នុងបំណងរង់ចាំស្តាប់ចំរៀងដែលខ្លួនបាននិពន្ធ។ នៅពេលដែលអ្នកចំរៀងចាប់ផ្តើមច្រៀងចំរៀងរបស់ខ្ញុំភ្លាម ខ្ញុំសឹងតែស្រក់ទឹកភ្នែក ពីព្រោះបទចំរៀង នេះ គឺចង់រៀបរាប់ពីជីវិតលំបាករបស់កម្មការនីរោងចក្រ ហើយខ្ញុំនឹកអាណិតខ្លួនឯងក៏ដូចជាកម្មការនីដ៏ទៃទៀតដែរ ។

ខ្ញុំមិនដែលគិតសោះថា ខ្ញុំនឹងអាចជាប់ជ័យលាភីនេះទេ ។ ខ្ញុំគ្រាន់តែចង់ស្តាប់បទរបស់ខ្ញុំ គឺវាគ្រាប់គ្រាន់ណាស់ទោហើយ ។ នៅពេលដែលគេប្រកាសឈ្មោះអ្នកឈ្នះ ខ្ញុំពិតជាចង់យំ និងមានមោទនភាពយ៉ាងខ្លាំង ចំពោះខ្លួនឯងដែល អាច ទទួលជ័យលាភីនេះ ។ ខ្ញុំចង់អរគុណ ដល់ឪពុកម្តាយរបស់ខ្ញុំ ដែលពួកគាត់បានបង្កើតខ្ញុំ និង ផ្តល់នូវសមត្ថភាពពិសេសនេះដល់ខ្ញុំ ។

នៅថ្ងៃអនាគតខ្ញុំចង់រៀនភាសាអង់គ្លេសបន្ថែមទៀត ដើម្បីមានការងារដែលល្អ ហើយនឹងចង់មានពេលគ្រប់គ្រាន់ដើម្បីបន្តការនិពន្ធរបស់ខ្ញុំ ។

ខ្ញុំមានតំលៃ

I am Precious

Garment Workers Value Campaign and Competition

| | | |
|---|---|---|
| I. | សំលេងរថយន្តលាចាកស្រុកទៅ<br>ខ្ញុំលាពុកម៉ែទាំងចិត្តទោម្នីញ | បើកបរសំដៅទៅក្រុងភ្នំពេញ<br>សង្ឃឹមវិលវិញបានប្រាក់ជូនម៉ែ ។ |
| II. | មកដល់ដីក្រុងក្នុងរោងចក្រមួយ<br>ការងាររោងចក្រកម្មករកាត់ដេរ | ដែលជាជំនួយពីប្រទេសគេ<br>បានប្រាក់ហូរហែរផ្ញើជូនទៅម្តាយ ។ |
| R. | ឱរោងចក្រអើយមានតែអ្នកហើយ<br>ជីវិតរុងរឿងអនាគតថ្លៃថ្លា | អោយខ្ញុំបានស្បើយរួចពីទុក្ខា<br>សង្គមគ្រួសារលែងជួបទុក្ខសោក ។ |
| III. | ម៉ែអើយនៅផ្ទះសូមម៉ែកុំព្រួយ<br>ការងាររោងចក្រមិនមានអៀនខ្មាស់ | ជីវិតកូនមួយមានតំលៃណាស់<br>ផ្តល់ផលច្រើនណាស់នៅក្នុងសង្គម ។ |

## ជ័យលាភីលេខ ២

## លោក រាជ សារ៉ាត់ អាយុ ២៩ ឆ្នាំ ធ្វើការនៅរោងចក្រ ភីស៊ីស៊ីអេស



ខ្ញុំធ្លាប់បានចូលរួមក្នុងកម្មវិធីប្រលងនេះពីមុនមក ដូច្នេះលើកនេះមិនសូវជាភ័យប៉ុន្មានទេ ។ ចំរៀងដែលខ្ញុំបាននិពន្ធគឺជាបទមួយដែលខ្ញុំចូលចិត្តខ្ញុំចំណាយពេលពីរថ្ងៃក្នុងការតែងបទនេះ ។ ទោះបីជាខ្ញុំមិនបានជាប់លេខមួយក៏ដោយ តែខ្ញុំអាចទទួលចំណាត់ថ្នាក់លេខ២ដែរ ។ ខ្ញុំមានការពេញចិត្តណាស់ពីព្រោះខ្ញុំបានសរសេរបទនេះដោយខ្លួនឯង។បន្ទាប់ពីបានចូលរួមក្នុងការប្រកួតនេះមក ខ្ញុំបានរៀននូវអ្វីថ្មីៗជាច្រើន ដែលអាចជួយដល់ការនិពន្ធរបសខ្ញុំអោយកាន់តែល្អឡើង។ហើយខ្ញុំទន្ទឹងរង់ចាំចូលរួមការប្រកួតម្តងទៀត នៅឆ្នាំក្រោយ ។

នៅពេលអនាគតខ្ញុំចង់បើកជាហាងតូចមួយនៅឯស្រុកកំណើត ហើយមួយវិញទៀតខ្ញុំចង់អោយកូនស្រីរបស់ខ្ញុំរៀនអោយបានខ្ពស់ដើម្បីក្លាយជាគ្រូពេទ្យម្នាក់ ។

ខ្ញុំមានតំលៃ
I am Precious
Garment Workers Value Campaign and Competition

**I.** ចំរៀងខ្ញុំច្រៀងមានន័យខ្លឹមសារ — ប្រាប់ដល់ខេមរាកម្មករប្រុសស្រី
រឿងពិតកម្មករខំប្រឹងរាល់ថ្ងៃ — បញ្ចេញស្នាដៃដើម្បីជួយជាតិ ។

**II.** កម្មករកម្ពុជាទាំងក្មេងទាំងចាស់ — ចាកចេញពីផ្ទះឃ្លាតអស់ផៅញាតិ
មករកការធ្វើចិញ្ចឹមជីវិត — ការងារសុច្ចរិតជួយសង្គមផង ។

**R.** ហ្នឹងហើយតំលៃកម្មកររោងចក្រ — ធ្វើការប្តូរប្រាក់ចិញ្ចឹមប្អូនបង
សូមកុំរើសអើងអោយតំលៃផង — ច្រើនឆ្នាំកន្លងឃ្លាតឆ្ងាយភូមិស្រុក ។

**III.** តែណ្ហើយខ្ញុំផ្តាំកម្មករប្រុសស្រី — រក្សាតំលៃ និង សេចក្តីសុខ
សូមកុំភ្លើតភ្លើនរឿងអបាយមុខ — នាំអោយមានទុក្ខអត់តំលៃយើង ។

## ជ័យលាភីលេខ ៣

## លោក ពេញ រដ្ឋា អាយុ ២៨ ឆ្នាំ ធ្វើការនៅរោងចក្រ ស៊ុបព្រីម



នេះគឺជាលើកទី ២ ហើយ ដែលខ្ញុំបានចូលរួមក្នុងការប្រកួតនិពន្ធបទចំរៀងនេះ ប៉ុន្តែខ្ញុំមិនដែលគិតថាវាជាកម្មវិធីធំដុំដូច្នេះទេ ។ កាលពីមុនខ្ញុំធ្លាប់ទទួលបានជ័យលាភីលេខ ១ តែពេលនេះខ្ញុំបែរជាបានជាប់លេខ៣ វិញ តែទោះជាយ៉ាងណាក៏ខ្ញុំនៅតែមានការរីករាយ ពីព្រោះខ្ញុំបានបញ្ចេញនូវសមត្ថភាពរបស់ខ្ញុំ ។

ខ្ញុំចូលចិត្តនិពន្ធបទដែលមានអត្ថន័យសប្បាយៗគឺដូចជាបទដែលខ្ញុំបានតែងដើម្បីចូលរួមប្រកួតនេះអញ្ចឹង។ មានហេតុផលពីរដែលធ្វើអោយខ្ញុំសំរេចចិត្តតែងបទនេះឡើង ។ ហេតុផលទី១ គឺខ្ញុំជាមនុស្សដែលចូលចិត្តផ្តល់សង្ឃឹមអោយខ្លួនឯង និងចូលចិត្តផ្តល់ជាមតិយោបល និងក្តីសង្ឃឹមដល់អ្នកដទៃ (កម្មកររោងចក្រទាំងអស់)។ ទោះបីជាយើងជាអ្នកក្រ តែយើងក៏មានតំលៃ ។ យើងពុំគួរអស់សង្ឃឹមចំពោះជីវិតឡើយ យើងគប្បីរស់នៅយ៉ាងរីករាយជាមួយអ្វីដែលយើងមាន ដូចជ ាអត្ថន័យ ក្ន ុងបទដែល ខ្ញុំបានតែងថា "សេចក្តីព្យាយាម គង់បានសំរេច" ប្រសិនបើយើងនៅតែព្យាយាមតស៊ូ ជីវិតរបស់យើងនឹងផ្លាស់ប្តូរទៅរកភាពប្រសើរឡើងនៅថ្ងៃអនាគត ។

នៅ ពេល អនាគត ខ្ញុំចង់ក្លាយទៅជា អ្នកជំនួញម្នាក់ ហើយសង្ឃឹមថាប្រពន្ធរបស់ ខ្ញុំ នឹ ងអាចឈប់ធ្វើក ារ ដើ ម្បីមានពេលគ្រាប់គ្រាន់សំរាប់ថែរក្សាគ្រួសារ និងកូនៗ ។

ខ្ញុំមានតំលៃ
I am Precious
Garment Workers Value Campaign and Competition

**I.** នៅក្នុងលោកាគ្រប់ជាតិសាសនាទាំងប្រុសទាំងស្រី ទោះខ្មៅសក្តីអ្នកក្រសេដ្ឋីក្មេងចាស់ជរា មានសិទ្ធិសេរី មានសិទ្ធិសេរី តំលៃស្មើគ្នា សិទ្ធិមានការងារមិនរើសអើងគ្នាប្រកាន់វណ្ណៈ ។

**II.** អ្នកមានអ្នកក្រទោះជាកម្មកររោងចក្រកាត់ដេរ មកពីស្រុកស្រែក៏ជាមនុស្សដែរយើងត្រូវស្មោះស្ម័គ្រ ត្រូវចេះជួយគ្នា ចេះស្រលាញ់គ្នា ដោយក្តីជឿជាក់ ទុកជាមិត្តភក្តិពូជសាសន៍វណ្ណៈយើងកុំប្រកាន់ ។

**III.** ទោះបីជាក្រទោះជាកម្មករក៏មានតំលៃ កុំតូចចិត្តអី ធ្វើការរាល់ថ្ងៃនឿយហត់កុំគិត ចេះមកពីរៀន មានពីខំរក ពាក្យចាស់ចែងពិត តស៊ូអំណត់ព្យាយាមប្រាកដថ្ងៃក្រោយបវរ ។

**IV.** ទោះការងារអ្វីក៏មានតំលៃសំរាប់ជាតិយើង គ្រួសាររុងរឿងជាតិយើងថ្កុំថ្កើន មានពលរដ្ឋល្អ មិនសេពគ្រឿងញៀន មិនលក់អាភៀន មិនដើរធ្វើចោរ គ្រួសារបវរ ឆ្លងផុតក្រីក្រជាតិរីកចំរើន ។

## អ្នកជាប់ជ័យលាភីរចនាម៉ូតសំលៀកបំពាក់

### ជ័យលាភីលេខ ១

### កញ្ញា សែម សុខនី អាយុ ១៨ ឆ្នាំ ធ្វើការនៅរោងចក្រ ម៉ាក់លីន



ខ្ញុំចំណាយពេលប្រមាណជា ៧ថ្ងៃដើម្បីគូរម៉ូតរូបមួយនេះ។ ខ្ញុំមិនមានសង្ឃឹមថានឹងឈ្នះក្នុងការប្រកួតនេះទេ ប៉ុន្តែថ្ងៃមួយមានមិត្ត ខ្ញុំ ម្នាក់បា នមកប្រា ប់ ខ្ញុំថា ខ្ញុំបានជាប់ក្នុងចំណោមគ្នា ១០ នាក់ហើយ ។ ខ្ញុំមានក្តីរំភើបណាស់ ប៉ុន្តែខ្ញុំស្ទើរតែបាត់បង់ឱកាសចូលរួមនៅវគ្គផ្តាច់ព្រ័ត្យនេះទៅហើយ។ នៅថ្ងៃមួយមានមនុស្ស ចំលែកពីរនាក់ ស្លៀកពាក់ស្អាតបាត មកសម្ភាសន៍ខ្ញុំ និងហៅខ្ញុំអោយ ទៅជាមួយ ពួកគាត់ តែខ្ញុំមិនទៅ ជាមួយ ពួកគាត់ទេ ព្រោះមិនដែលស្គាល់ខ្លាចពួកគាត់ជាមនុស្សមិនល្អ តែផ្ទុយទៅវិញគាត់ជាមនុស្សល្អសោះ ខ្ញុំមានការសោកស្តាយណាស់ ។ សំណាងល្អពួកគាត់បានត្រលប់មកសួរខ្ញុំម្តងទៀត ហើយលើកនេះខ្ញុំត្រូវតែទៅ ។



នៅថ្ងៃផ្តាច់ព្រាត់មកដល់ខ្ញុំសប្បាយចិត្តណាស់នៅពេលគណៈកម្មការប្រកាសឈ្មោះអ្នកជាប់លេខ២ និងលេខ៣ខ្ញុំបិទភ្នែកហើយគិតថា ខ្ញុំមិនអាច ជាប់លេខ ១ នោះទេ ប៉ុន្តែ ខ្ញុំស្ទើរតែហើបជើងពីដី នៅពេលដែលគេប្រកាសថាខ្ញុំជាប់លេខ ១ ព្រោះមិនគួរអោយជឿ ។ ម្តាយរបស់ខ្ញុំនឹងរៀបចំសង់បន្ទប់ថ្មីសំរាប់ខ្ញុំ ចំណែកកង់ខ្ញុំជិះទៅធ្វើការរាល់ថ្ងៃ ចំពោះរ៉ូបខ្ញុំនឹងថែរក្សាវាអោយបានល្អព្រោះវាជាសមត្ថភាពរបស់ខ្ញុំផ្ទាល់ ។

ឥឡូវនេះ ខ្ញុំល្បីឈ្មោះ នៅក្នុង រោងចក្រ ហើយមិត្តរួមការងារទាំងអស់ ជំរុញអោយខ្ញុំបន្តនូវការច្នៃម៉ូតទៀត ។

ខ្ញុំមានតំលៃ
I am Precious
Garment Workers Value Campaign and Competition

## ជ័យលាភីលេខ ២

## អ្នកស្រី ប៉ុល គន្ធា អាយុ ៣៥ ឆ្នាំ ធ្វើការនៅរោងចក្រ ម៉ាក់លីន



កាលពីនៅតូចខ្ញុំចូលចិត្តយកស្លឹកចេកមកកាត់ហើយគូរជាម៉ូត ខោអាវ ។ ខ្ញុំមិនដែលគិតថា នឹង មានឱកាសអាចចូលរួម ប្រកួតបែបនេះទេ ។ ខ្ញុំរីករាយ ខ្លាំងណាស់សំរាប់ការជាប់ជ័យលាភីលេខ ២ នេះ ។

នៅថ្ងៃដែល ខ្ញុំចុះឈ្មោះ ចូលរួមប្រកួត ដំបូងខ្ញុំគ្មានសង្ឃឹមថាជាប់ទេតែបន្ទាប់ពីខ្ញុំ បានជាប់ក្នុងចំណោមដប់នាក់មក ខ្ញុំភ្ញាក់ផ្អើល និង រំភើប រីករាយជាខ្លាំង ជាពិសេសនៅថ្ងៃ ប្រកួតផ្តាច់ព្រ័ត្រ មកដល់ ខ្ញុំត្រូវឈរនៅលើឆាក ។ នៅពេល ដែល ខ្ញុំលឺថា ខ្ញុំជាប់ ជ័យលាភី លេខ ២ ដៃទាំងពីរ របស់ខ្ញុំ ឡើងញ័រ បេះដូងខ្ញុំស្ទើរលោតចេញមកខាងក្រៅទៅហើយ ។ខ្ញុំរីករាយចំពោះរង្វាន់របស់ខ្ញុំ ណាស់ ។ខ្ញុំសង្ឃឹម ថា នឹងមាន ការប្រកួត បែបនេះទៀតនៅពេលក្រោយ ហើយខ្ញុំនឹងចូលរួម និង លេងស្លូវខ្លាចទៀតហើយ។



នៅថ្ងៃអនាគត ខ្ញុំចង់បើកជា ហាងកែសម្លូសមួយ ដើម្បីជួយអោយជីវិតភាព បានល្អ និង មានលទ្ធភាពគ្រប់គ្រាន់សំរាប់អោយកូនៗ រៀនរហូតដល់ចប់ ។

ខ្ញុំមានតំលៃ
I am Precious
Garment Workers Value Campaign and Competition

## ជ័យលាភីលេខ ៣

## អ្នកស្រី គឹម យុនគង្គារ អាយុ ២៤ ឆ្នាំ ធ្វើការនៅរោងចក្រ វីលសុន



ខ្ញុំបានគូររ៉ូបរបស់ខ្ញុំដោយផ្តើមចេញពីការច្នៃទង់ជាតិខ្មែរ ។ ខ្ញុំចូលចិត្តគូររូបនៅលើក្រដាសដោយមិនប្រើពណ៌ច្រើនទេ។ ខ្ញុំចំនាយពេលប្រហែលជាពីរម៉ោងក្នុងការគូរម៉ូតនេះដោយប្រើតែប៊ិចក្រហម និង ប៊ិចខៀវប៉ុណ្ណោះ។

ខ្ញុំរំភើបចិត្តខ្លាំងណាស់នៅពេលបានដឹងថា ខ្លួនអាចចូលរួមប្រកួត នៅវគ្គផ្តាច់ព្រ័ត្រ ហើយត្រូវឈរនៅលើ ឆាកនៅ ពីមុខទស្សនិកជន ជាង ៥០ ០នាក់ ដែលវាក ាន់តែធ្វើអេ ាយខ្ញុំរឹតតែ ភ័យឡើង ។ នៅពេលគេប្រកាសឈ្មោះខ្ញុំ ជាអ្នកជាប់ជ័យលាភី លេខ ៣ ខ្ញុំ មានអារម្មណ៍ សប្បាយចិត្តយ៉ាងខ្លាំង ហើយជើងរបស់ខ្ញុំ ទាំង ២ ស្ទើរតែហើបផុតពីដី។ ខ្ញុំមានមោទនភាពចំពោះខ្លួនឯ ងណាស់ ហើយខ្ញុំស្រឡាញ់រង្វាន់របស់ខ្ញុំណាស់ ខ្ញុំថែរក្សាវាបានយ៉ាងល្អនៅក្នុងបន្ទប់របស់ខ្ញុំ ។

នៅថ្ងៃអនាគត ខ្ញុំចង់ក្លាយជាអ្នកច្នៃម៉ូតសំលៀកបំពាក់ និងចង់មានហាងផ្ទាល់ខ្លួនមួយ ។



សំរាប់ព័ត៌មានបន្ថែមអំពី ការប្រកួតនេះ សូមចូលមើល វេបសាយ ចុងក្រោយបង្អស់ រឺក៏អាច ទំនាក់ទំនង អ្នកស្រី ប៉ូល វណ្ណា តាមរយៈអ៊ីម៉ែល vanna@ilo.org រឺកញ្ញា មីនណា ម៉ាសកូឡា តាមរយៈអ៊ីម៉ែល maaskola@ilo.org